# ព្រះធម្មបទ៣១គាថា



ចំណងដៃឆ្នាំថ្មី

រៀបរៀងដោយ

ភិក្ខុវជិរប្បញ្ញោ **សាន សុជា**

សម្រាប់ជាធម្មទាន



# បុគ្គលឯក

"បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ តើបុគ្គលឯកនោះគឺនរណា ?

**គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ"**

# មាតាបិតាមានឈ្មោះ៤យ៉ាង



ភិក្ខុវជិរប្បញ្ញោ **សាន សុជា** និងញោមប្រុសស្រី

១- ជា "ព្រះព្រហ្ម" របស់កូន

២- ជា "បុព្វទេវតា" របស់កូន

៣- ជា "បុព្វាចារ្យ" របស់កូន

៤- ជា "អាហុនេយ្យបុគ្គល" របស់កូន

# មាតិកាអត្ថបទ

ឈ្មោះធម៌ ទំព័រ

ពាក្យប្រារព្ធ ........................................ ក

## VI- គាថាព្រះធម្មបទ បណ្ឌិតវគ្គ (ត)

គាថាទី ១ ........................................ ១

គាថាទី ២ ........................................ ៣

គាថាទី ៣ ........................................ ៥

គាថាទី ៤ ........................................ ៧

គាថាទី ៥ ........................................ ៩

គាថាទី ៦ ........................................ ១១

## VII- គាថាព្រះធម្មបទ អរហន្តវគ្គ

គាថាទី ៧ ........................................ ១៥

គាថាទី ៨ ........................................ ១៧

គាថាទី ៩ ........................................ ១៩

គាថាទី ១០ ........................................ ២១

គាថាទី ១១ ........................................ ២៣

គាថាទី ១២ ............................................ ២៥
គាថាទី ១៣ ............................................ ២៧
គាថាទី ១៤ ............................................ ២៩
គាថាទី ១៥ ............................................ ៣១
គាថាទី ១៦ ............................................ ៣៣

## VIII- គាថាព្រះធម្មបទ សហស្សវគ្គ

គាថាទី ១៧ ............................................ ៣៥
គាថាទី ១៨ ............................................ ៣៧
គាថាទី ១៩ ............................................ ៣៩
គាថាទី ២០ ............................................ ៤១
គាថាទី ២១ ............................................ ៤៣
គាថាទី ២២ ............................................ ៤៥
គាថាទី ២៣ ............................................ ៤៧
គាថាទី ២៤ ............................................ ៤៩
គាថាទី ២៥ ............................................ ៥១
គាថាទី ២៦ ............................................ ៥៣

គាថាទី ២៧ ........................................ ៥៥

គាថាទី ២៨ ........................................ ៥៧

គាថាទី ២៩ ........................................ ៥៩

គាថាទី ៣០ ........................................ ៦១

IX- គាថាព្រះធម្មបទ បាបវគ្គ

គាថាទី ៣១ ........................................ ៦៣

ឧបមាគុណព្រះរតនត្រៃម្ភៃពីរប្រការ ..................... ៦៥

គោតមប្រវត្តិ ( កំណាព្យ) ............................ ៧៨

នាទីកំណាព្យផ្សេងៗ ................................ ៨៣

ឈ្មោះអ្នកជួយពិនិត្យអក្ខរាវិរុទ្ធ ...................... ១២៤

ឈ្មោះសៀវភៅដែលបានរៀបរៀង ......................... ១២៥

ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយ ........................ ១២៦

ឈ្មោះអ្នកឧបត្ថម្ភប្រាក់បោះពុម្ពសៀវភៅនេះ ............ ១២៧

# ពាក្យផ្ដើម

ពុទ្ធបរិស័ទទាំងឡាយ ! ពេលវេលានៃការរស់នៅរបស់មនុស្សយើងនេះ មិនសម្បូណ៌ឡើយ ធ្លេចបើក១ ជិតដល់ពេលស្លាប់ទៅវិញទៅហើយ ហើយចំពោះជីវិតដែលខ្លីយ៉ាងនេះ តើយើងធ្លាប់បានគិតដែរឬទេថា ការងារជាប្រយោជន៏សម្រាប់ខ្លួនឯងអាត្មាអញធ្វើបានប៉ុនណាហើយ ? និងការងារដែលមិនទាន់ធ្វើ នៅមានអ្វីខ្លះទៀត ? ម្យ៉ាងទៀតការងារជាប្រយោជន៏ដល់អ្នកដទៃ និងជាប្រយោជន៏ដល់ប្រទេសជាតិ ឬក៏ដើម្បីព្រះសាសនា អាត្មាអញធ្វើបានប៉ុនណាហើយ ? តទៅខាងមុខនឹងធ្វើអ្វីទៀត ?

កាលបើយើងឧស្សាហ៏គិតយ៉ាងនេះ យើងពិត

ជាយល់ឃើញនូវតម្លៃពិតប្រាកដ របស់ពេលវេលា មិនខានឡើយ ។

តាមដែលខ្ញុំដឹង អ្នកប្រាជ្ញសម័យបុរាណខ្លះ ដូចជាសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន-ណាត** ជាដើម បានចំណាយពេលវេលាអស់មួយជីវិត របស់លោកទៅហើយ ក្នុងការបំពេញការងារដើម្បី ខ្លួនព្រះអង្គផ្ទាល់ ដើម្បីព្រះសាសនា និងដើម្បីប្រទេស ជាតិ ប៉ុន្តែក៏នៅមិនទាន់អស់កិច្ចការជាប្រយោជន៏ ដែលត្រូវបំពេញនោះដែរ ។

ដែលខ្ញុំលើកឡើងយ៉ាងនេះ ដើម្បីដាស់គំនិត យើងគ្រប់គ្នាថា បើពេលវេលាមិនសម្បូណ៌យ៉ាងនេះ ហេតុអ្វីក៏យើងនៅតែចំណាយពេលវេលា ទៅក្នុងរឿង

ឥតប្រយោជន៍ផ្សេងៗ ដូចជាការដើរលេងយប់ ការប្រព្រឹត្តអបាយមុខ ឬក៏និយាយគ្នាលេងជាដើមច្រើនម្ល៉េះ ? តើទាំងអស់គ្នានោះ ក្នុងម្នាក់ៗមានជីវិតប៉ុន្មាន ? ហើយអាចរស់នៅបានពេលយូរប៉ុនណាទៀត ? បើមិនបានបំពេញការងារជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃទេ តើខ្លឹមសារនៃការរស់នៅយូរនោះ នៅត្រង់ណាខ្លះទៅ ? សូមពុទ្ធបរិស័ទបានពិចារណាដោយល្អចុះ។

ឆ្នាំថ្មីនេះគឺឆ្នាំកុរ នព្វស័ក ព.ស ២៥៥១ ខ្ញុំមានអាយុ៣១ឆ្នាំទៅហើយ ឃើញថាចាស់ដែរហើយ ឯមច្ចុរាជ ក៏បានបញ្ជូនសេនាមកចាត់ការជារៀងរាល់ថ្ងៃ ហើយការយកឈ្នះលើមច្ចុរាជនោះ មិនមានសោះ

ឡើយ សេចក្តីស្លាប់ពិតជាមកដល់មិនខាន តែខ្ញុំពេញចិត្តណាស់ចំពោះពេលវេលា ដែលបានអនុញ្ញាតឱ្យខ្ញុំបំពេញការងារជាប្រយោជន៍បានបន្តិចបន្តួច ដូចសព្វថ្ងៃនេះ មុនពេលដែលសេចក្តីស្លាប់មកដល់។

ដើម្បីវាស់វែងទៅនឹងពេលវេលា ៣១ ឆ្នាំ ដែលខ្ញុំបានរស់កន្លងមកហើយ ខ្ញុំក៏លើកបទធម៌ចំនួន ៣១ ព្រះគាថា មកសរសេរប្រគេននិងចែកជូនជាធម្មទានក្នុងឱកាសបុណ្យចូលឆ្នាំថ្មីខាងមុខនេះ។

ដោយអំណាចនៃធម្មទាននេះ សូមឱ្យពុទ្ធបរិស័ទគ្រប់ទីឋាន និងគ្រប់វ័យ បានជួបប្រទះនូវប្រយោជន៍គ្រប់ប្រការ សូមអនុមោទនា !!!

-សូមឧទ្ទិសនូវបុណ្យកុសល ដែលកើតឡើង

អំពីការងារធម្មទាននេះថ្វាយចំពោះ សម្តេចព្រះសង្ឃ-រាជ ជោតញ្ញាណោ **ជួន-ណាត** ដែលជាវីរបុរសក្នុងចិត្តនៃខ្ញុំ និងបុរាណបណ្ឌិតខ្មែរគ្រប់ជំនាន់។

-សូមឧទ្ទិសចំពោះ ព្រះតេជព្រះគុណ ព្រះនាម **ញៀម ទ៊ាន់** ជាព្រះគ្រូឧបជ្ឈាយ៍របស់ខ្ញុំ និងលោកគ្រូអាចារ្យទាំងឡាយរបស់ខ្ញុំ។

-សូមជូនចំពោះញោមប្រុស **សាន-ឌុយ** និងញោមស្រី **អៀង-ថែម** ដែលកំពុងមានជីវិតនៅឡើយ និងពពួកញាតិក្នុងសង្សារវដ្តទាំងអស់។

មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ឃុំរលាប ស្រុកសំពៅមាស

ខេត្តពោធិ៍សាត់ ប្រទេសកម្ពុជា

ថ្ងៃអង្គារ ៧រោច ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០

**ភិក្ខុវរបញ្ញោ សាន-សុជា**

# គាថាទី ១ (១)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវលកុណ្ដកភទ្ទិយត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**សេលោ យថា ឯកឃនោ**

**វាតេន ន សមីរតិ**

**ឯវំ និន្ទាបសំសាសុ**

**ន សម្មិញ្ជន្តិ បណ្ឌិតា ។**

ភ្នំថ្មតាន់ មិនរំភើបព្រោះខ្យល់ ដូចម្ដេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នោះឯង ។

---

១-បើរាប់តាមលំដាប់ក្នុងបណ្ឌិតវគ្គ ត្រូវជាគាថាទី ៦ ។

វីជាតិភ្នំថ្ម    គាន់ណែនរឹងល្អ រាងធំហើយខ្ពស់

ទោះបីត្រូវខ្យល់ ឬមួយត្រូវព្យុះ ក៏មិនរង្គោះ

រង្គើញាប់ញ័រ។

យ៉ាងណាបណ្ឌិត ដែលបានប្រព្រឹត្ត តាមលំអានធម៌

លោកមានចិត្តនឹង ដូចជាភ្នំថ្ម    រលកលោកធម៌

បោកលែងកក្រើក។

៦កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវស្ត្រីជាមាតានៃនាងកាណា ទើបត្រាស់នូវព្រះគាថានេះថា

**យថាបិ រហទោ គម្ភីរោ**

**វិប្បសន្នោ អនាវិលោ**

**ឯវំ ធម្មានិ សុត្វាន**

**វិប្បសីទន្តិ បណ្ឌិតា ៗ**

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួន យ៉ាងនោះ ។

អន្លង់ទឹកធំគឺសមុទ្រ ធំជ្រៅបំផុតហួសគណនា
ជាទីត្រាច់ចរនៃមច្ឆា ហិចហែលផ្កាប់ផ្ងារយ៉ាងសប្បាយ ។
ទោះហ្វូងមច្ឆាច្រើនដល់ម៉្លោះ ក៏សមុទ្រនោះមិនអាចក្លាយ
ទៅជាទឹកល្អក់គួរនឿយណាយ ប្រុសស្រីជិតឆ្ងាយចង់គយគន់ ។
សូម្បីសត្វលោកទាំងសកល ឬស្តេចទ្រង់ពលសម្បូរធន
ទ្រង់មានសេនារាប់រយពាន់ ក៏នៅមិនទាន់មានអាជ្ញា ។
បញ្ជាកងទ័ពខ្លាំងបំផុត ឱ្យកូរសមុទ្រគ្រប់វេលា
សមុទ្រនៅតែមានទឹកថ្លា គឺគ្មានអ្នកណាឱ្យល្អក់បាន ។
យ៉ាងណាបណ្ឌិតអ្នកស្តាប់ធម៌ កម្ចាត់កករក្នុងសន្តាន
ជាសាវកស្មោះព្រះទ្រង់ញាណ គ្មានអ្នករំខានបានទៀតឡើយ ។

៧កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវពួកភិក្ខុប្រមាណ ៥០០ រូប ទើបត្រាស់នូវព្រះគាថានេះថា

**សព្វត្ថ វេ សប្បុរិសា វជន្តិ**
**ន កាមកាមា លបយន្តិ សន្តោ**
**សុខេន ផុដ្ឋា អថ វា ទុក្ខេន**
**ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។**

ពួកសប្បុរស តែងលះ (ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូរ ព្រោះសេចក្ដីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្ដីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្ដែងអាការឡើងចុះឡើយ ។

អន្លង់ទឹកធំគឺសមុទ្រ ធំជ្រៅបំផុតហួសគណនា
ជាទីត្រាច់ចរនៃមច្ឆា ហិចហែលផ្កាប់ផ្ងារយ៉ាងសប្បាយ ។
ទោះហ្វូងមច្ឆាច្រើនដល់ម៉្លោះ ក៏សមុទ្រនោះមិនអាចក្លាយ
ទៅជាទឹកល្អក់គួរនឿយណាយ ប្រុសស្រីជិតឆ្ងាយចង់គយគន់ ។
សូម្បីសត្វលោកទាំងសកល ឬស្តេចទ្រង់ពលសម្បូរធន
ទ្រង់មានសេនារាប់រយពាន់ ក៏នៅមិនទាន់មានអាជ្ញា ។
បញ្ជាកងទ័ពខ្លាំងបំផុត ឱ្យកូរសមុទ្រគ្រប់វេលា
សមុទ្រនៅតែមានទឹកថ្លា គឺគ្មានអ្នកណាឱ្យល្អក់បាន ។
យ៉ាងណាបណ្ឌិតអ្នកស្ទាប់ធម៌ កម្ចាត់កករក្នុងសន្តាន
ជាសាវកស្មោះព្រះទ្រង់ញាណ គ្មានអ្នករំខានបានទៀតឡើយ ។

៧កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវពួកភិក្ខុប្រមាណ ៥០០ រូប ទើបត្រាស់នូវព្រះគាថានេះថា

**សព្វត្ថ វេ សប្បុរិសា វជន្តិ**
**ន កាមកាមា លបយន្តិ សន្តោ**
**សុខេន ផុដ្ឋា អថ វា ទុក្ខេន**
**ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។**

ពួកសប្បុរស តែងលះ ( ឆន្ទរាគៈ ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអ្ងរ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

ឃើញស្អាតព្រោះស្រឡាញ់

ដឹងថាឆ្ងាញ់ព្រោះតែឃ្លាន

ខ្លាចក្រព្រោះចង់មាន

ចង់ក្សេមក្សាន្តព្រោះខ្លាចទុក្ខ ។

បើកាត់តែចំណង់

ពិតស្រោចស្រង់បានគ្រប់មុខ

រាគៈប្រភពទុក្ខ

ចង់បានសុខត្រូវលះបង់ ។

៨កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះធម្មិកត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**ន អត្តហេតុ ន បរស្ស ហេតុ**
**ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ**
**ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ**
**ស សីលវា បញ្ញវា ធម្មិកោ សិយា ។**

បណ្ឌិតមិនគួរធ្វើអាក្រក់ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

ជាតិជាបណ្ឌិត　　មិនគួរប្រព្រឹត្ត　　អំពើពាលា
ព្រោះហេតុតែខ្លួន　　ឬបុត្រធីតា　　ព្រោះហេតុភរិយា
ឬទ្រព្យសម្បត្តិ ។

ទោះបីប្រាថ្នា　　ទ្រព្យឬកូនភ្ញា　　ក៏ត្រូវប្រយ័ត្ន
ត្រូវរក្សាខ្លួន　　ឱ្យបានទៀងទាត់　　ក្រែងមានវិបត្តិ
មានភ័យដល់ប្រាណ ។

មិនគប្បីខ្ជិល　　ត្រូវតែមានសីល　　ធមិល្អកល្យាណ
ត្រូវមានបញ្ញា　　ឆ្ការបាបសាមាន្យ　　ទើបទទួលបាន
សុខកាយស្បើយចិត្ត ។

៩កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវរឿងនៃកិរិយាស្ដាប់នូវធម៌ ទើបត្រាស់នូវព្រះគាថានេះថា

**អប្បកា តេ មនុស្សេសុ យេ ជនា បារគាមិនោ**
**អថាយំ ឥតរា បជា តីរមេវានុធាវតិ ។**
**យេ ច ខោ សម្មទក្ខាតេ ធម្មេ ធម្មានុវត្តិនោ**
**តេ ជនា បារមេស្សន្តិ មច្ចុធេយ្យំ សុទុត្តរំ ។**

បណ្ដាមនុស្សទាំងឡាយ ពួកជនណាដែលឆ្លងដល់ត្រើយគឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌

ដែលព្រះតថាគត ទ្រង់ត្រាស់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

អ្នកបានដល់ត្រើយគឺនិព្វាន កម្រនឹងមានក្នុងលោកា
ព្រោះនិព្វានល្អិតហួសឧបមា បើខ្វះបញ្ញាឃើញមិនបាន។
អ្នកជាប់ត្រើយអាយគឺទិដ្ឋិ ច្រើនក្រាស់ប៉ប្រែះហួសការស្មាន
ព្រោះមានមោហ៍បាំងចិត្តសន្តាន យល់ថាមានប្រាណក្នុងលោកីយ៍។
តែបើជនណាបានត្រងត្រាប់ គោរពតាមច្បាប់ព្រះជិនស្រី
ជននោះនឹងឆ្លងផុតភពបី ផុតចាកដែនដីនៃមច្ចុ។

១០កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវអាគន្តុកភិក្ខុប្រមាណ ៥០០ រូប ទើបត្រាស់នូវព្រះគាថានេះថា

**កណ្ហំ ធម្មំ វិប្បហាយ**

**សុក្កំ ភាវេថ បណ្ឌិតោ**

**ឱកា អនោកមាគម្ម**

**វិវេកេ យត្ថ ទូរមំ**

**តត្រាភិរតិមិច្ឆេយ្យ**

**ហិត្វា កាមេ អកិញ្ចនោ**

បរិយោទបេយ្យ អត្តានំ

ចិត្តក្លេសេហិ បណ្ឌិតោ ។

យេសំ សម្ពោធិយង្គេសុ

សម្មា ចិត្តំ សុភាវិតំ

អាទានប្បដិនិស្សគ្គេ

អនុបាទាយ យេ រតា

ខីណាសវា ជុតិមន្តោ

តេ លោកេ បរិនិព្វុតា ។

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញ៉ាំងធម៌ស

ឱ្យចម្រើនឡើង (ដោយវិធី) ចេញចាកអាល័យគឺ

កាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្មជាត មិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុង វិវេកដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិត គួរញ៉ាំងខ្លួនឱ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត។ ចិត្ត ដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយ ក្នុងអង្គ នៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំង-ឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវ សេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជា អ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វាន ក្នុងលោក។

ធម៌ខ្មៅកើតក្នុងចិត្តជនណា

ជននោះខ្លោចផ្សាគ្មានក្ដីសុខ

ធម៌ខ្មៅជាហេតុឱ្យកើតទុក្ខ

អ្នកចង់បានសុខត្រូវលះបង់ ។

គួរដុះខាត់ចិត្តគិតឱ្យល្អ

ចម្រើនធម៌សឱ្យផ្ទូរផង់

ធម៌សពិតអាចជួយស្រោចស្រង់

សត្វពីអន្លង់ក្ដីទុក្ខបាន ។

គួរលះអាល័យគឺកាមគុណ

អន្លង់ទុក្ខធ្ងន់ក្នុងសន្ដាន

ចម្រើនវិវេកធម៌កល្យាណ

ទើបទទួលបានក្សេមក្សាន្តពិត ។

១១កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ៧ (១)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង ព្រៃស្វាយនៃពេទ្យឈ្មោះជីវកៈ ទ្រង់ប្រារព្ធនូវបញ្ហា ដែលពេទ្យឈ្មោះជីវកៈទូលសួរ ទើបត្រាស់នូវ ព្រះគាថានេះថា

**គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោក អ្នកមានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង (មានខន្ធជាដើម) មាន កិលេសជាគ្រឿងចាក់ស្រែះទាំងពួងលះបង់ហើយ ។

---

១-បើរាប់តាមលំដាប់ក្នុងអរហន្តវគ្គ ត្រូវជាគាថាទី ១ ។

ជីវិតគឺជាការដើរផ្លូវឆ្ងាយ

ឯរូបរាងកាយជាសាលាសំណាក់

ផ្លូវឆ្ងាយគឺជាឈ្មោះនៃវដ្ដៈ

ក្រាស់ដោយអន្ទាក់នៃមច្ចុមារ ។

មច្ចុគឺជាស្ដេចមានអំណាច

គម្រាមបន្លាចសត្វលោកគ្រប់គ្នា

ដែលប្រកាន់យកបញ្ចក្ខន្ធា

ធ្វើជាអត្តាឬជាខ្លួនប្រាណ ។

តែធីរជនអ្នកសុន្ទរីគំនិត

អ្នកបានប្រព្រឹត្តទៅតាមលំអាន

ឃើញច្បាស់ថាខន្ធមិនមែនជាប្រាណ

តែងរួចចាកឋាននៃមច្ចុមារ ។

១២កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រះមហាកស្សបត្ថេរ ទើប ត្រាស់នូវព្រះគាថានេះថា

**ឧយ្យុញ្ជន្តិ សតីមន្តោ**
**ន និកេតេ រមន្តិ តេ**
**ហំសាវ បល្ល់ ហិត្វា**
**ឱកមោកំ ជហន្តិ តេ ៕**

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែង ខ្វល់ខ្វាយ រមែងត្រេកអរ ក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចហង្ស លះបង់ភក់ហើរទៅ ដូច្នោះ ។

ព្រះខីណាស្រព លោកលះអភ័ព្វ គឺកាមគុណ

ដែលជាមូលហេតុ នៃក្តីទារុណ អន្ទង់ទុក្ខធ្ងន់

គឺសង្សារា ។

លោកមានស្មារតី សង្វាតឃ្មាតខ្មី ដោយក្តីហានក្លា

ប្រតិបត្តិដោយស្មោះ អស់ពីចិន្តា ដូចហង្សបក្សា

ហើរចាកអន្លង់ ។

១៣កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



# គាថាទី ៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះពេឡដ្ឋសីសត្ថេរ ទើប ត្រាស់នូវព្រះគាថានេះថា

**យេសំ សន្និចយោ នត្ថិ**
**យេ បរិញ្ញាតភោជនា**
**សុញ្ញតោ អនិមិត្តោ ច**
**វិមោក្ខោ យេស គោចរោ**
**អាកាសេវ សកុន្តានំ គតិ តេសំ ទុរន្នយា ។**

ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខជាគោចរ គតិ គឺដំណើររបស់ពួកជននោះៗ គេកម្រដឹងបាន ដូច ដំណើរនៃពួកសត្វស្លាបព្ធដ៏អាកាស ដូច្នោះ ។

ជនណាអ្នកសង្រួម    រវាំងព្រមដោយស្មារតី
អត់ធន់ដោយខន្តី    ប្រោសប្រណីក្នុងអាហារ ។

មិនធីតាមចំណង់    មិនលិចលង់តាមតណ្ហា
ហើយមានវិមោក្ខា    ចរយាត្រាតាមលំអាន ។

ជននោះពិតប្រសើរ    មានដំណើរលំបាកស្មាន
ដូចបក្សីចំណាន    ហើរក្បៀមក្បាន្តព្ធដ៏មេឃ ។

១៤កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រះអនុរុទ្ធត្ថេរ ទើប ត្រាស់នូវព្រះគាថានេះថា

**យស្សាសវា បរិក្ខីណា**
**អាហារេ ច អនិស្សិតោ**
**សុញ្ញតោ អនិមិត្តោ ច**
**វិមោក្ខោ យស្ស គោចរោ**
**អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ៕**

ជនណាអស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហានិងទិដ្ឋិ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួក សត្វស្លាបក្នុងអាកាស ដូច្នោះ ។

ព្រះអរិយៈ អ្នកប្រចក្ស ច្បាស់និព្វាន
មានសន្តាន ក្សាន្តសុខពិត ឥតកង្វល់
គ្មានគំនិត គិតអាក្រក់ អកុសល
ព្រោះបានស្គាល់ យល់បានច្បាស់ អស់សង្ស័យ ។
លះតណ្ហា ឆ្ការទិដ្ឋិ ធមិថោកទាប
មិនធ្វើបាប ព្រោះអាហារ ចម្អែតផ្ទៃ
មានវិមោក្ខ ជាគោចរ ល្អប្រពៃ
ដូចបក្សី រួចចាកភ័យ ពួងមេឃ ។

១៥កើត ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តបុព្វារាម ទ្រង់ប្រារព្ធនូវព្រះមហាកច្ចាយនត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យស្សិន្ទ្រិយានិ សមថង្គតានិ**
**អស្សា យថា សារថិនា សុទន្តា**
**បហីនមានស្ស អនាសវស្ស**
**ទេវាបិ តស្ស បិហយន្តិ តាទិនោ ។**

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីហ្វឹកហ្វឺនរាបហើយ សូម្បីទេវតានិងមនុស្សទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹងមិនញាប់ញ័រ ។

សត្វលោកតែងប្រកាន់ គំនរខន្ធថាជាខ្លួន

បន្ថែមអម្រែកផ្ទួន តម្កើងខ្លួនដោយមានះ ។

តែព្រះខីណាស្រព កាត់អភ័ព្វដោយស្រឡះ

ដំណើរលឿនរហ័ស ដូចជាសេះអាជានេយ្យ ។

ព្រោះលោកលះស្រឡះ ធម៌មានះឥតអាល័យ

ពួកជនជ្រះថ្លាក្រៃ ព្រោះឥន្ទ្រិយស្ងប់រម្ងាប់ ។

១រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះសារីបុត្តត្ថេរ ទើបត្រាស់ នូវព្រះគាថានេះថា

**បឋវីសមោ នោ វិរុជ្ឈតិ**

**ឥន្ទខីលូបមោ តាទិ សុព្វតោ**

**រហទោវ អបេតកទ្ទមោ**

**សំសារា ន ភវន្តិ តាទិនោ ។**

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។

ភិក្ខុល្អ តែងត្រាច់ចរ តាមធម្មា
ភិក្ខុល្អ មានសទ្ធា ពិតប្រាកដ
ភិក្ខុល្អ មានចិត្តស្ងប់ មិនកម្សត់
ភិក្ខុល្អ ពិតជារត់ រួចចាកទុក្ខ ។
ព្រោះបានដឹង ខន្ធធាតុហ្នឹង ដោយបញ្ញា
ព្រោះបានដឹង ថាលោកា គ្មានក្តីសុខ
ព្រោះបានដឹង ថាកិលេស ប្រភពទុក្ខ
ព្រោះបានដឹង កំពូលសុខ គឺនិព្វាន ។

២រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវសាមណេរនៃព្រះតិស្សត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**សន្តន្តស្ស មនំ ហោតិ**

**សន្តា វាចា ច កម្ម ច**

**សម្មទញ្ញា វិមុត្តស្ស**

**ឧបសន្តស្ស តាទិនោ ។**

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែង មានដល់លោកដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាករាគាទិក្កិលេស) ជាអ្នកស្ងប់រម្ងាប់ ដូច្នោះ ។

ចិត្តដែលស្ងប់ គឺជាចិត្ត មានកម្លាំង
ចិត្តដែលស្ងប់ ពិតអាចច្បាំង នឹងកិលេស
ចិត្តដែលស្ងប់ ធម៌គ្រោតគ្រាត មិនចាក់ស្រែះ
ចិត្តដែលស្ងប់ ពួកកិលេស មិនមើលងាយ ។
វាចាស្ងប់ ពិតជាទ្រព្យ ក្នុងលោកីយ៍
វាចាស្ងប់ ជនប្រុសស្រី ឥតជិនណាយ
វាចាស្ងប់ នាំសត្វលោក ឱ្យសប្បាយ
វាចាស្ងប់ នាំឃ្លាតឆ្ងាយ ពីអរិធី ។
កាយកម្មស្ងប់ ពិតជាទ័ព ដ៏ពូកែ
កាយកម្មស្ងប់ អាចបង្វែរ ពួកធម៌ហីន៍
កាយកម្មស្ងប់ នាំបានសុខ រួចចាកភ័យ
កាយកម្មស្ងប់ ព្រះមុនី តែងសរសើរ ។

៣រោច ខែកត្តិក ឆ្នាំច ព.ស២៥៤០



## គាថាទី ១៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះសារីបុត្តត្ថេរ ទើបត្រាស់ នូវព្រះគាថានេះថា

**អស្សទ្ធោ អកតញ្ញូ ច**

**សន្ធិច្ឆេទោ ច យោ នរោ**

**ហតាវកាសោ វន្តាសោ**

**សវេ ឧត្តមបោរិសោ ។**

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះ និព្វានផង កាត់នូវគ្រឿងតគីវដ្តៈផង មានឱកាសកម្ចាត់ បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

អ្នកមានសទ្ធាពិតប្រាកដ

មិនអាចភ្លាំងភ្លាត់ជឿរឿងផ្សេង

ខុសចាកព្រះធម៌ព្រះសម្តែង

ថ្លាថ្លែងរឿងពិតមានខ្លឹមសារ ។

ព្រោះបានឃើញច្បាស់ព្រះនិព្វាន

តាមព្រះទ្រង់ញាណត្រាស់ទេសនា

បានកាត់ទីតវដ្តសង្សារ

ចាត់ថាឧត្តមបុរសពិត ។

៤រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះខទិរវនិយរេវតត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**គាមេ វា យទិ វារញ្ញេ**
**និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ**
**តំ ភូមិរាមណេយ្យកំ ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជា ស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯងជាភូមិ គួរត្រេកអរ ។

និគមឬជនបទ ស្រុកក្រខ្សត់ឬទីព្រៃ
ទីឆ្ងាយដាច់អាល័យ ឬទីដីមិនរាបស្មើ ។

ទីទួលឬទីទាប វាលទំនាបសព្វសារពើ
ទីនោះពិតប្រសើរ ដោយសារមានព្រះអរហន្ត ។

ទោះវេលាកន្លង ឆ្នាំរំលងរាប់រយពាន់
ទីនោះពិតសោភ័ណ ក្លាយជាបូជនីយដ្ឋាន ។

៥រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវស្ត្រីមួយរូប ទើបត្រាស់នូវ ព្រះគាថានេះថា

**រមណីយានិ អរញ្ញានិ**

**យត្ថ ន រមតី ជនោ**

**វីតរាគា រមេស្សន្តិ**

**ន តេ កាមគវេសិនោ ។**

ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរ ក្នុងព្រៃដែលគួរីករាយទេ ព្រះខីណាស្រពដែលមាន រាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

អ្នកស្វែងកាម ពិតរបហាម ខ្វះជានិច្ច
អ្នកស្វែងកាម វង្វេងភ្លេច ក្នុងលោកិយ៍
អ្នកស្វែងកាម ដូចមមាច នឹងអគ្គី
អ្នកស្វែងកាម មិនបេតី ព្រឹក្សព្រៃស្ងាត់ ។

ខីណាស្រព មិនទាក់ជាប់ នឹងកាមា
ខីណាស្រព មានបញ្ញា ឥតវិបត្តិ
ខីណាស្រព ពិតត្រេកអរ នឹងព្រៃស្ងាត់
ខីណាស្រព ពិតជាកាត់ អស់រាគៈ ។

៦រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ១៧[១]

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវបុរសអ្នកសម្លាប់ចោរឈ្មោះតម្ពទាឋិកៈ ទើបត្រាស់នូវព្រះគាថានេះថា

**សហស្សមបិ ចេ វាចា**
**អនត្ថបទសញ្ហិតា**
**ឯកំ អត្ថបទំ សេយ្យោ**
**យំ សុត្វា ឧបសម្មតិ ។**

បើវាចា សូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ អ្នកណាស្ដាប់នូវបទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

---

១-បើរាប់តាមលំដាប់ក្នុងសហស្សវគ្គ ត្រូវជាគាថាទី ១ ។

និយាយពាក្យរោយរាយ　ពាក្យឃ្លាតឆ្ងាយពីប្រយោជន៍
ពាក្យនោះនាំបង្ខោច　រោចបង្ខិនតែខ្លួនឯង ។
ណាមួយខាតការងារ　ណាវាចាគ្មានគេក្រែង
ទោះខំប្រឹងសម្តែង　ដូចជាផ្សែងគ្មានខ្លឹមសារ ។
វាចាត្រឹមមួយបទ　តែផ្សៀងផ្ទាត់ដោយបញ្ញា
អ្នកស្តាប់ស្ងប់ចិន្តា　ចាត់ទុកថាប្រសើរក្រៃ ។
តួយ៉ាងព្រះវាចា　ពាក្យទេសនាព្រះចមត្រៃ
នៅតែមានតម្លៃ　អ្នកចេះឆ្នៃបានប្រយោជន៍ ។

៧រោច ខែកត្តិក ឆ្នាំច ព.ស២៥៤០

# គាថាទី ១៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរៈឈ្មោះទារុចិរិយៈ ទើបត្រាស់នូវព្រះគាថានេះថា

**សហស្សមបិ ចេ គាថា**
**អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ**
**យំ សុត្វា ឧបសម្មតិ ។**

បើគាថា សូម្បីមួយពាន់ ជាគាថាប្រកបដោយ បទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់ បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

គាថាវាចាកាព្យ ពាក្យថោកទាបរាប់រយពាន់
ជាបទមិនសោភ័ណ គ្មានខ្លឹមសារពុំប្រសើរ។
តែបើគាថាណា ប្រាប់មាគ៌ាឱ្យដំណើរ
នាំសព្វសត្វឱ្យធ្វើ នូវអំពើកុសលា។
ហើយបានស្ដាប់រម្ងាប់ បានបញ្ចប់សង្សារា
សូម្បីមួយបទណា ក៏ចាត់ថាប្រសើរក្រៃ។

៨រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ១៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរឈ្មោះកុណ្ឌលកេសី ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា**
**ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**
**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។**

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៏ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធមិហើយ រមែងស្ងប់រម្ងាប់បាន បទនៃធមិនោះសូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយពាន់ៗដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

ការឈ្នះសង្គ្រាមរាប់រយពាន់លាន
ទន្ទ្រានមានប្រៀបលើខ្មាំងគ្រប់គ្នា
សម្តេចទ្រង់ញ្ញាណព្រះភគវា
មិនឱ្យនាមថាអ្នកប្រសើរពិត ។
លុះតែអ្នកណាឈ្នះលើខ្លួនឯង
ព្យាយាមខ្នះខ្នែងប្រឹងទូន្មានចិត្ត
អ្នកនោះទើបឈ្មោះថាប្រសើរពិត
អ្នកប្រាជ្ញព្រេងព្រឹទ្ធតែងពោលសរសើរ ។

៩រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



# គាថាទី ២០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រាហ្មណ៍អ្នកសួរនូវហេតុ មិនជាប្រយោជន៍ ទើបត្រាស់នូវព្រះគាថានេះថា

**អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា**
**អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ**
**នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា**
**ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។**

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែក ពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរ ឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នក ប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំង

ព្រហ្ម មិនគប្បីធ្វើនូវជម្នះ របស់សត្វមានសភាព ដូច្នោះ ឱ្យត្រឡប់ចាញ់វិញបានឡើយ ។

ឈ្នះខ្លួនឯង ព្រះសម្តែង ថាប្រសើរ
ជាដំណើរ មិនត្រឡប់ ចាញ់ពេលក្រោយ
ឈ្នះអ្នកក្រៅ ថ្ងៃក្រោយទៅ ពិតជាធ្លោយ
ដល់ថ្ងៃស៊យ ត្រូវគេចង ពៀរវេរា ។
បើដូច្នេះ គួរកុំធ្វេស ចេះថែថួន
រក្សាខ្លួន ពួនពីបាប គ្រប់ប្រការ
ទើបបានឈ្នះ ពិតប្រាកដ អត់វេរា
គន្ធពូមារ គ្មានអាជ្ញា ឱ្យចាញ់បាន ។

១០រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ២១

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ជាឪពុកធំនៃ ព្រះសារីបុត្តត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

អ្នកណាបូជា (លោកិយមហាជន) ដោយទ្រព្យមួយពាន់រាល់ៗខែ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជាអស់

មួយរយឆ្នាំនោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរ
ឡើយ ។

| | |
|---|---|
| អ្នកណាបានបូជា | ដោយទ្រព្យាដល់មហាជន |
| ផ្ទុកដោយកិលេសធ្ងន់ | ជន់ដោយបាបអកុសល ។ |
| ដូចអ្នកយកស្រូវពូជ | រលួយខូចស្មើរគ្មានសល់ |
| ទៅព្រោះលើទីទួល | ផលាផ្តល់មិនប្រសើរ ។ |
| តែអ្នកដែលបូជា | ដោយសទ្ធាពារទៅលើ |
| អរិយៈអ្នកប្រសើរ | អ្នកមានខ្លួនអប់រំហើយ ។ |
| ដូចអ្នកយកស្រូវពូជ | មិនទាន់ខូចខាតនៅឡើយ |
| ព្រោះលើដីភ្លួរហើយ | ផលនឹងឱ្យលើសការស្មាន ។ |

១១រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ២២

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្តត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជន្តុ អគ្គិំ បរិចរេ វនេ ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

ជនណា បម្រើភ្លើងក្នុងព្រៃអស់មួយរយឆ្នាំ ចំណែកអ្នកណា បូជាលោកដែលមានខ្លួនអប់រំហើយតែមួយនាក់ សូម្បីមួយរំពេច ការបូជានោះឯងប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

វិការបូជា    មានបែបផ្សេងគ្នា    សន្ទឹកសន្ទាប់
ខ្លះក៏បូជា    តាមតែទម្លាប់    ខ្លះទៀតធ្វើផ្គាប់
ចិត្តគ្រូអាចារ្យ ។

ធ្វើច្រើនប៉ុន្មាន    តែបើមិនបាន    ប្រកបបញ្ញា
ទោះបូជាយូរ    រាប់រយវស្សា    ក៏គ្មានខ្លឹមសារ
ព្រោះខ្វះស្មារតី ។

ដូចជាពួកព្រាហ្មណ៍    ធ្វើតាមទំនៀម    បម្រើអគ្គី
ខុសចាកគន្លង    ធម៌ព្រះមុនី    យល់ថាអគ្គី
ផ្តល់ក្តីសុខា ។

តែធីរជន    ប្រកបដោយគុណ    ពោលគឺបញ្ញា
បានបូជាត្រូវ    តាមព្រះសាស្តា    ទោះតិចយ៉ាងណា
ចាត់ថាប្រសើរ ។

១២រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ២៣

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនូវព្រាហ្មណ៍ជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ**

**សំវច្ឆរំ យជេថ បុញ្ញបេក្ខោ**

**សព្វំបិ តំ ន ចតុភាគមេតិ**

**អភិវាទនា ឧជ្ជុគតេសុ សេយ្យោ ។**

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿសក្ការ-បូជា ធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង។

ទាយកគំនិតសុន្ទរ៍ ប្រាថ្នាបុណ្យហើយបូជា
សក្ការៈនានា អស់វេលាមួយវស្សា។
ដល់ជនអ្នកខូចខិល អត់មានសីលរីលបញ្ញា
បើគិតពីផលា ពិតជាតិចពេកកន្លង។
បើចែកដោយចំណែក មិនបានផ្ដែកទីបូនផង
នឹងអ្នកត្រូវគន្លង បូជាអ្នកប្រព្រឹត្តត្រង់។

១៣រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



# គាថាទី ២៤

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃ ជិតនគរទីឃលម្ពិកៈ ទ្រង់ប្រារព្ធនូវអាយុវឌ្ឍនកុមារ ទើបត្រាស់នូវព្រះគាថានេះថា

**អភិវាទនសីលិស្ស**

**និច្ចំ វុឌ្ឍាបចាយិនោ**

**ចត្តារោ ធម្មា វឌ្ឍន្តិ**

**អាយុ វណ្ណោ សុខំ ពលំ ។**

ធម៌៤ប្រការគឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែងដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

ពរ៤ប្រការ សត្វក្នុងលោកា ប្រាថ្នាចង់បាន
ទីមួយអាយុ ពីរសុខក្សេមក្សាន្ត ទីបីចង់បាន
វណ្ណៈស្រស់ល្អ ។
គម្រប់ទីបួន កម្លាំងមាំមួន គឺពលៈធមិ
ជាពរប្រសើរ ថ្លៃថ្លាបវរ ព្រះអង្គព្យាករណ៍
ទាំងបួនប្រការ ។
ពរនេះកើតពី គោរពវន្ទីយ៍ ព្រះត្រៃរតនា
ឬមួយចំពោះ អ្នកមានសីលា ឬចាស់ព្រឹទ្ធា
ជាប្រក្រតី ។

១៤រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០

## គាថាទី ២៥

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវសង្កិច្ចសាមណេរ ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**
**ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ**
**សីលវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង។

រស់រយឆ្នាំ តែមិនចាំ សីលសិក្ខា
រស់រយឆ្នាំ កាយវាចា មិនសុភាព
រស់រយឆ្នាំ ឫកចរិយា មិនរាបទាប
រស់រយឆ្នាំ គ្មានរបៀប បង់អសារ ។
រស់មួយថ្ងៃ តែចេះលៃ ឆ្នៃអំពើ
រស់មួយថ្ងៃ ប្រព្រឹត្តធ្វើ ឫករាបសា
រស់មួយថ្ងៃ មិនប្រមាទ សព្វកិច្ចការ
រស់មួយថ្ងៃ មានសីលា ប្រសើរជាង ។

១៥រោច ខែកត្តិក ឆ្នាំច ព.ស២៥៥០



## គាថាទី ២៦

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះខានុកោណ្ឌញ្ញត្ថេរ ទើប ត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**

**ទុប្បញ្ញោ អសមាហិតោ**

**ឯកាហំ ជីវិតំ សេយ្យោ**

**បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិន មានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែ មួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យ ពិចារណាជាប្រក្រតី ប្រសើរជាង ។

រស់រយឆ្នាំ តែមិនយល់ អត្ថធម៌អាថ៌
រស់រយឆ្នាំ គ្មានប្រាជ្ញា ក្នុងការគិត
រស់រយឆ្នាំ មិនអប់រំ បន្ទុំចិត្ត
រស់រយឆ្នាំ គ្មានគំនិត ឥតខ្លឹមសារ ។
រស់មួយថ្ងៃ ឆ្អែតគំនិត គិតពិសោធ
រស់មួយថ្ងៃ មិនល្ងង់ឆោត រាល់កិច្ចការ
រស់មួយថ្ងៃ មានគំនិត គិតពិចារណ៏
រស់មួយថ្ងៃ មានប្រាជ្ញា ប្រសើរជាង ។

១កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៤០



## គាថាទី ២៧

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះសប្បទាសត្ថេរ ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**

**កុសីតោ ហីនវីរិយោ**

**ឯកាហំ ជីវិតំ សេយ្យោ**

**វីរិយំ អារភតោ ទឡ្ហំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តរួញរួមងប់ ក្នុងអកុសលវិតក្កៈ មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួនប្រសើរជាង ។

រស់រយឆ្នាំ ត្រាំក្នុងធម៌ វិតក្កៈ
រស់រយឆ្នាំ ចិត្តប្រឡាក់ អកុសល
រស់រយឆ្នាំ ការព្យាយាម មិនដិតដល់
រស់រយឆ្នាំ ចិត្តខ្វាយខ្វល់ គ្មានសិរី ។
រស់មួយថ្ងៃ មិនទុកពេល ឱ្យកិលេស
រស់មួយថ្ងៃ មិនប្រហែស ធ្វេសស្មារតី
រស់មួយថ្ងៃ ខំព្យាយាម តាមមុនី
រស់មួយថ្ងៃ ប្រឹងឃ្មាតខ្មី ប្រសើរជាង ។

២កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០

## គាថាទី ២៨

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរីឈ្មោះបដាចារា ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**

**អបស្សំ ឧទយព្វយំ**

**ឯកាហំ ជីវិតំ សេយ្យោ**

**បស្សតោ ឧទយព្វយំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញនូវការកើតឡើងនិងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញនូវការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

រស់រយឆ្នាំ ត្រាំដោយធម៌ អវិជ្ជា
រស់រយឆ្នាំ ខ្វះបញ្ញា វិលគំនិត
រស់រយឆ្នាំ មិនដឹងធម៌ រលត់ពិត
រស់រយឆ្នាំ មិនដែលគិត រឿងសង្ខារ ។
រស់មួយថ្ងៃ មានគំនិត គិតរហ័ស
រស់មួយថ្ងៃ បានដឹងច្បាស់ នូវធម្មា
រស់មួយថ្ងៃ ឃើញធម៌កើត ប្រែអនិច្ចា
រស់មួយថ្ងៃ ដឹងសង្ខារ ប្រសើរជាង ។

៣កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០

## គាថាទី ២៩

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវនាងកិសាគោតមី ទើប ត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**

**អបស្សំ អមតំ បទំ**

**ឯកាហំ ជីវិតំ សេយ្យោ**

**បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញនូវ បទឈ្មោះអមតៈ (គឺព្រះនិព្វាន) ការរស់នៅសូម្បីតែ មួយថ្ងៃ របស់លោកអ្នកឃើញនូវបទឈ្មោះអមតៈ ប្រសើរជាង ។

រស់រយឆ្នាំ តែមិនឃើញ ធម៌អមតៈ
រស់រយឆ្នាំ មិនប្រចក្ស ព្រះនិព្វាន
រស់រយឆ្នាំ មិនយកធម៌ ធ្វើជាយាន
រស់រយឆ្នាំ ឆ្ងាយនិព្វាន គ្មានសុខសាន្ត។

រស់មួយថ្ងៃ រួចចាកភ័យ ដល់អមតៈ
រស់មួយថ្ងៃ បានប្រចក្ស ព្រះនិព្វាន
រស់មួយថ្ងៃ សម្បូរដោយ បញ្ញាញាណ
រស់មួយថ្ងៃ ឃើញនិព្វាន ប្រសើរជាង។

៤កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០



## គាថាទី ៣០

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះថេរី ឈ្មោះពហុបុត្តិកា ទើបត្រាស់នូវព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ**
**អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំ សេយ្យោ**
**បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញនូវធម៌ដ៏ខ្ពង់ខ្ពស់ (គឺនវលោកុត្តរធម៌) ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញនូវធម៌ដ៏ខ្ពង់ខ្ពស់ប្រសើរជាង ។

រស់រយឆ្នាំ មិនសន្សំ នូវបញ្ញា
រស់រយឆ្នាំ មិនកាប់ឆ្ការ ធម៌អបលក្ខណ៍
រស់រយឆ្នាំ មិនបានឃើញ លោកុត្តរៈ
រស់រយឆ្នាំ ជាប់អន្ទាក់ គ្មានគ្រាន់បើ ។
រស់មួយថ្ងៃ តែឆ្លាតវៃ មានបញ្ញា
រស់មួយថ្ងៃ ញាណភ្លឺថ្លា មិនស្មាក់ស្មើរ
រស់មួយថ្ងៃ បានឃើញធម៌ ដ៏ប្រសើរ
រស់មួយថ្ងៃ មានដំណើរ ប្រសើរពិត ។

៥កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០



## គាថាទី ៣១ (១)

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុង វត្តជេតពន ទ្រង់ប្រារព្ធនូវចូឡេកសាដកព្រាហ្មណ៍ ទើបត្រាស់នូវព្រះគាថានេះថា

**អភិត្ថរេថ កល្យាណេ**

**បាបា ចិត្តំ និវារយេ**

**ទន្ធំ ហិ ករតោ បុញ្ញំ**

**បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺត យូរ ចិត្តរមែងត្រេកអរក្នុងបាប ។

១-បើរាប់តាមលំដាប់ក្នុងបាបវគ្គ ត្រូវជាគាថាទី ១ ។

អ្នកចង់បានសុខ គួរតែសម្រុក ប្រញាប់សាងល្អ
លះក្តីប្រមាទ សង្វាតធម៌ស កសាងគុណធម៌
ប្រចាំសន្តាន។
កុំធ្វេសប្រហែស កុំអាងមានលេស ថាធ្វើមិនបាន
ព្រោះខ្លួននៅក្មេង ទ្រព្យមិនសូវមាន ចាំរកទ្រព្យបាន
ធ្វើឱ្យអស់ដៃ។
បើអាងយ៉ាងនេះ ពិតជាគ្មានផេះ លុះជីវិតក្ស័យ
ព្រោះថាបន្ទូរ ឱ្យបាបបានដៃ ពិតជាគ្មានថ្ងៃ
រួចចាកទុក្ខឡើយ។

៦កើត ខែមិគសិរ ឆ្នាំច អដ្ឋស័ក ព.ស២៥៥០



# (ឧបមាគុណព្រះរតនត្រៃ ២២ ប្រការ)

វីគុណព្រះត្រៃរតន៍ បរិសុទ្ធប្រសើរក្រៃ
លោកបានឧបមេយ្យ មានម្តៃពីរប្រការ ។
✲ ទីមួយគឺព្រះពុទ្ធ ប្រសើរផុតត្រៃលោកា
ប្រៀបដូចព្រះចន្ទ្រា រះនាថ្ងៃពេញបូណ៌មី ។
វីឯព្រះធម្មា ប្រៀបដូចជាកម្ទរស្មី
នៃដួងព្រះចន្ទថ្លៃ ចាំងរស្មីភ្លឺលោកា ។
ព្រះសង្ឃដូចលោកហ្នឹង បានទីពឹងព្រោះចន្ទ្រា
ចែងចាំងរស្មីថ្លា ឱ្យលោកាល្អពេកក្រៃ ។
✲ ទីពីរព្រះភគវា ប្រៀបដូចជាអាទិត្យថ្លៃ
រះឡើងនៅពេលថ្ងៃ មានរស្មីខ្លាំងមហិមា ។

ព្រះធម៌នៃព្រះអង្គ ផូរផង់ដូចអាភា
ចេញពីអាទិត្យថ្លា ដេញអន្ធការឱ្យខ្ចាត់ទៅ ។
ព្រះសង្ឃអង្គសាវ័ក មានសំវរៈល្អពេកកូវ
ដូចទ្វីបលោកដែលត្រូវ អាទិត្យក្តៅឱ្យភ្លឺថ្លា ។
✲ ទីបីព្រះមុនី ឥតមានពីរក្នុងលោកា
ព្រះអង្គប្រៀបដូចជា អ្នកអុជភ្លើងឆួលដុតព្រៃ ។
រីអង្គព្រះធម្មា ប្រៀបដូចជាភ្លើងក្តៅក្រៃ
ដុតព្រៃស្មៅចង្រៃ ជាសត្រូវនឹងស្រូវស្រែ ។
ព្រះសង្ឃនោះឯងនៃ ឧបមេយ្យដូចដីស្រែ
ដែលម្ចាស់ខិតខំថែ ក្លាយជាស្រែដ៏ឧត្តម ។
✲ ទីបួនព្រះភគវា ប្រៀបដូចជាភ្លៀងយ៉ាងធំ

ប្រយោជន៍ដ៏ឧត្តម តែងកើតមានដល់លោកា ។
ព្រះធម៌ព្រះទ្រង់ញាណ ដែលទ្រង់បានប្រោសទេសនា
ដូចដំណក់ទឹកថ្លា ស្រោចដណ្ដប់លើផែនដី ។
សាវ័កអ្នកហ្មត់ចត់ ដូចជនបទពណ៌ខៀវខ្ចី
ដែលភ្លៀងទើបធ្លាក់ថ្មី គួរប្រុសស្រីទាក់នេត្រា ។
✲ ទីប្រាំព្រះសម្ពុទ្ធ ប្រសើរផុតជននានា
ព្រះអង្គប្រៀបដូចជា សារថីដ៏ចំណាប់ ។
រីឯព្រះធម៌ថ្លៃ ឧបមេយ្យដូចជាច្បាប់
ឧបាយជាគ្រឿងចាប់ បង្ហឹកសេះអាជានេយ្យ ។
ព្រះសង្ឃដ៏សោភា ប្រៀបដូចជាអាជានេយ្យ
ហ្វឹកហាត់ល្អប្រពៃ អាចលៃប្រើទាន់ចិន្តា ។

✲ ប្រាំមួយនោះឯងនៃ    ល្អពេកក្រៃព្រះសាស្តា
ព្រះអង្គប្រៀបដូចជា    សល្យពេទ្យសម្រាប់ដកសរ ។
ព្រះធម៌នៃព្រះអង្គ    មានបែបទ្រង់សែនបវរ
ដូចឧបាយដកសរ    គឺទិដ្ឋិសត្វគ្រប់គ្នា ។
សង្ឃសាវ័កកល្យាណ    លោកប្រៀបបាននឹងអ្នកណា
ដែលសរមុតកាយា    ត្រូវគ្រូពេទ្យដកចេញបាន ។
✲ ប្រាំពីរព្រះសម្ពុទ្ធ    បរិសុទ្ធប្រៀបស្មើបាន
ចក្ខុពេទ្យចំណាន    ចេះឧបាយបកនេត្រា ។
ព្រះធម៌វិសេសថ្លៃ    ឧបមេយ្យឧបាយា
បកភ្នែកជននានា    ឱ្យភ្លឺថ្លាផុតជំងឺ ។
រីឯព្រះសង្ឃា    ប្រៀបដូចជាអ្នកភ្នែកឈឺ

ត្រូវពេទ្យបកឱ្យភ្លឺ ចាកងងឹតគឺមោហា ។

✲ ប្រាំបីព្រះភគវន្ត អរហន្តជាសាស្តា
ព្រះអង្គប្រៀបដូចជា ពេទ្យមានប្រាជ្ញាឆ្លាតវៃ ។

ព្រះធម៌ដ៏កល្យាណ ប្រៀបស្មើបានឱសថថ្លៃ
ដែលពេទ្យមានស្នាដៃ ឆ្នៃផ្សំត្រូវយ៉ាងចំណាន ។

ព្រះសង្ឃរតន៍ថ្លៃ ឧបមេយ្យអ្នកដែលបាន
សះស្បើយរោគសាមាន្យ គឺកិលេសគ្រប់ប្រការ ។

✲ ប្រាំបួនព្រះទ្រង់ញាណ ប្រៀបអ្នកបានស្គាល់មាគ៌ា
បង្ហាញសត្វគ្រប់គ្នា ឱ្យទៅរកទីផុតភ័យ ។

រីឯព្រះធម្មា ដែលសាស្តាទ្រង់លកលៃ
ត្រាស់ទុកដល់សព្វថ្ងៃ ឧបមេយ្យផ្លូវសុខា ។

ចំពោះព្រះសង្ឃរតន៍ បរិសុទ្ធឥតមាយា
ប្រៀបដូចប្រុសស្រីណា ដើរដល់ទីដែលក្សេមក្សាន្ត។
✻ ទីដប់ព្រះសាស្តា មានបញ្ញារុងរឿងថ្កាន
ប្រៀបដូចព្រៃហេមពាន្ត ពេញទៅដោយដើមរុក្ខា។
ព្រះធម៌ដូចដើមថ្នាំ ដុះប្រចាំគ្រប់វេលា
គុណភាពល្អអស្ចារ្យ នៅក្នុងទីព្រៃហេមពាន្ត។
ព្រះសង្ឃល្អសោភា ប្រៀបដូចជាអ្នកដែលបាន
ឱសថព្រៃហេមពាន្ត ផឹករួចហើយស្បើយរោគា។
✻ ដប់មួយព្រះមានជោគ ដូចនាយទូកក្នុងជលសា
តែងមានចិត្តករុណា ដល់សព្វសត្វក្នុងភពត្រៃ។
ព្រះធម៌ពាក្យទូន្មាន ប្រៀបស្មើបានទូកចរណៃ

ចម្លងផុតលោកត្រៃ ឱ្យដល់ត្រើយបានសុខា។
ព្រះសង្ឃដ៏និមល ដូចអ្នកដល់ត្រើយហើយណា
ត្រើយនោះមានឈ្មោះថា ព្រះនិព្វានសែនសុខក្រៃ។
✲ ដប់ពីរព្រះភគវា ជាសាស្ដាបញ្ញាវៃ
ព្រះអង្គឧបមេយ្យ អ្នកឱ្យទ្រព្យគាប់ចិន្ដា។
ព្រះធម៌ទាំងប៉ុន្មាន ប្រៀបស្មើបានទ្រព្យនោះណា
ដែលជនផងនានា តែងប្រាថ្នារៀងរាល់ថ្ងៃ។
សង្ឃសាវ័កកល្យាណ ដូចអ្នកបានចាយទ្រព្យថ្លៃ
គុណភាពល្អពេកក្រៃ .ចាយរួចបានសុខគួរគាប់។
✲ ដប់បីព្រះនិរភ័យ ឧបមេយ្យអ្នកមានភ័ព្វ
បង្ហាញរូវណ្ដៅទ្រព្យ ឱ្យដល់អ្នកដែលត្រូវការ។

ព្រះធម៌ពាក្យប្រដៅ ដូចរណ្តៅទ្រព្យនោះណា
ពេញដោយទ្រព្យនានា មានតម្លៃហួសការស្មាន ។
ព្រះសង្ឃអ្នកស្តាប់ទ្រង់ ផ្លូវផង់រុងរឿងថ្កាន
ប្រៀបដូចជាអ្នកបាន រណ្តៅទ្រព្យរីករាយក្រៃ ។
✲ ជប់បួនព្រះធម៌ភព ល្អសព្វគ្រប់គ្មានទោសពៃរ៍
ព្រះអង្គប្រសើរក្រៃ ដូចជាវីរបុរស ។
ព្រះធម៌ពាក្យបង្រៀន ប្រៀបស្មើបានក្តីផុតគ្រោះ
ក្សេមក្សាន្តឥតមានមោះ មានតែសុខគ្រប់ប្រការ ។
ព្រះសង្ឃដ៏សមទ្រង់ វិសុទ្ធិវង្សចិញ្ចែងថ្លា
ដូចអ្នកបានសុខា ដោយសារវីរបុរស ។
✲ ជប់ប្រាំព្រះសម្ពុទ្ធ បរិសុទ្ធសមទាំងអស់

ប្រៀបដូចសប្បុរស អ្នកលួងលោមឱ្យបានស្បើយ។
រីព្រះសទ្ធម្មា ប្រៀបដូចការលួងនោះហើយ
លួងលោមឱ្យបានល្ហើយ ស្បើយក្តីសោករោគចង្រៃ។
ព្រះសង្ឃសាវ័កពុទ្ធ ដូចអ្នកផុតរួចចាកភ័យ
ឧបទ្រពកំណាចក្រៃ ព្រោះស្នាដៃនៃព្រះអង្គ។
✲ ដប់ប្រាំមួយនោះណា ព្រះសាស្តាវិសុទ្ធិវង្ស
ព្រះទ័យស្អាតស្មោះត្រង់ ប្រៀបប្រដូចនឹងមិត្តល្អ។
រីឯពាក្យទេសនា រចនាជាបទធម៌
ដូចពាក្យមិត្តបវរ ប្រាប់ប្រយោជន៍ដល់មិត្តភ្ងា។
ព្រះសង្ឃឧត្តមពិត អ្នកនៃបនិត្យព្រះធម្មា
ប្រៀបដូចនឹងអ្នកណា បានប្រយោជន៍គាប់ហឫទ័យ។

✲ ដប់ប្រាំពីរព្រះនិរទុក្ខ ល្អគ្រប់មុខហួសវិស័យ
ព្រះអង្គឧបមេយ្យ បឹងកើតទ្រព្យច្រើនប្រការ ។
ព្រះធម៌ល្អគួរគាប់ ដូចជាទ្រព្យមានខ្លឹមសារ
កើតក្នុងបឹងនោះណា ជនត្រូវការកើបយកបាន ។
ព្រះសង្ឃស្វាមីភ័ក្តិ ប្រៀបដូចអ្នកសំណាងមាន
ជួបទ្រព្យបឹងកល្យាណ រមែងបានក្តីរីករាយ ។
✲ ដប់ប្រាំបីព្រះសុគត ល្អវិសុទ្ធិមិនទទន់ជ្រាយ
ប្រៀបធៀបអធិប្បាយ អ្នកភ្ជួតទឹករាជកុមារ ។
បណ្តាំនៃព្រះអង្គ សមបែបទ្រង់គ្រប់ប្រការ
ប្រៀបដូចនឹងទឹកថ្លា សម្រាប់ងូតជម្រះកាយ ។
ព្រះសង្ឃប្រៀបដូចជា រាជកុមារបានសប្បាយ

ងូតទឹកត្រជាក់សាយ ជ្រះអស់ក្តែលពីកាយា។

✻ ដប់ប្រាំបួនព្រះជិនស្រី មានសិរីឈ្មោះក្រុងមារ

ព្រះអង្គប្រៀបដូចជា អ្នកធ្វើគ្រឿងប្រដាប់កាយ ។

ព្រះធម៌ពាក្យបណ្តាំ ពីរពាន់ប្រាំរយឆ្នាំប្លាយ

ដូចគ្រឿងប្រដាប់កាយ ពេញនិយមគ្រប់វេលា ។

សាវ័កព្រះទ្រង់ញាណ ដែលលោកបានស្តាប់ទេសនា

ដូចអ្នកល្អសោភា ព្រោះអលង្ការធម្មក្ខន្ធ ។

✻ ទីម្ភៃនោះឯងណា ឧបមាព្រះភគវន្ត

ដូចគ្នានឹងដើមចន្ទន៍ ប្រកបក្លិនមានតម្លៃ ។

រីឯព្រះសទ្ធម្ម ដ៏ឧត្តមសមប្រពៃ

ដូចក្លិនចន្ទន៍ចរណៃ ដែលប្រុសស្រីគួចប្រាថ្នា ។

សាវ័កអ្នកស្មោះត្រង់ អ្នកទ្រទ្រង់សីលសិក្ខា
ដូចជានរៈណា ស្រង់ក្លិនចន្ទន៍ឈ្មុយពេកពិត ។
✲ ម្តេមួយព្រះបិតា ជាសាស្តាទ្រង់មានឫទ្ធិ
ដូចផ្តល់ទឹកអម្រឹត ដល់កូនស្ងួនទាំងប្រុសស្រី ។
រីព្រះសទ្ធម្មណា ដែលសាស្តាពោលស្រដី
ទេសនាយ៉ាងឃ្មាតខ្មី ប្រៀបដូចទឹកអម្រឹតហ្នឹង ។
ព្រះសង្ឃប្រៀបដូចជា អ្នកកំព្រាតតទីពឹង
បានទឹកអម្រឹតហ្នឹង មានពំនឹងរួចមរណា ។
✲ ម្តេពីរព្រះគោតម ដូចបទុមក្នុងជលសា
សូរ្យសែងរះកាលណា រីកសាខាស្រស់ឆើតឆាយ ។
ព្រះធម៌ប្រៀបដូចជា ទឹកដមផ្កាឈ្ងុកទាំងឡាយ

គួរស្រូបតតជិនណាយ　　មាននៅក្នុងបទុមផ្កា ។

ព្រះសង្ឃអង្គសាវ៉ក　　អ្នកជឿជាក់ត្រៃសិក្ខា

ប្រដូចនឹងភូមរា　　បានក្រេបផ្កាក្នុងវ៉ារី ។

✲ ឧបមាគុណត្រៃរតន៍　　មានប្រាកដម្លៃពីរ

ដែលខ្ញុំខំសម្ដី　　សូត្រវន្ទិយ៍នមស្ការ ។

សូមឱ្យសម្រេចបុណ្យ　　ដែលជាគុណល្អថ្លៃថ្លា

អន្ទោលក្នុងសង្សារ　　សូមប្រាថ្នាជួបបណ្ឌិត ។

សូមជួបព្រះសិអារ្យ　　ជាសាស្ដាដ៏ពិសិដ្ឋ

សូមចាក់ធ្លុះធម៌ពិត　　សមដូចចិត្តប្រាថ្នាហោង ។

ថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំរក ឆស័ក ព.ស២៥៤៨

# គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្តាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន ។
មកចាប់ផ្ទៃមាតា ស្រីស្រីង្គារស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ
នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។

ឆ្នាំចពិសាខនា ថ្ងៃសុខជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្ងួយ អភិសេកនឹងស្រីង្គារ ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។
កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃបានសុខា ។
ស្ដេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឱ្យព្រះរាជា ស្ដេចជំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្ដាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។

បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រាសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី
អាសាធពេញបូណ៌មី ក្សត្រាថ្លៃចេញបព្វជ្ជា ។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្រកិរិយា គ្មាននរណាធ្វើដូចអី ។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្ដាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា អាសាធមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្ដើមពោលស្ដីធម៌ទេសនា ។

ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្តា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឃើញនៅឃើនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា
គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។

សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ ជាសាស្ដាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

៣.ស២៥៤៦



# នាទីកំណាព្យផ្សេងៗ

## ព្រះគុណម្ចាស់ជាបុរសផ្កាយ

គួរជ្រះថ្លា នឹងសទ្ធា ព្រះគុណម្ចាស់
កម្រណាស់ លះបង់កាយ ថ្វាយព្រះទ័យ
គោរពជឿ ស្ម័គ្រស្មោះលើ គុណកែវបី
ធម៌វិន័យ ក៏ម្ចាស់ថ្លៃ បដិបត្តិបាន ។
លោកព្យាយាម ត្រាច់ចរតាម ពុទ្ធោវាទ
មិនព្រមឃ្លាត ស្នាមព្រះបាទ ព្រះទ្រង់ញាណ
មិនងាករេ ពីទិសដៅ ទៅនិព្វាន
លោកសមមាន ព្រះនាមជា បុរសផ្កាយ ។
រីឯមនុស្ស ស្លឹកឈើជ្រុះ ខ្វះអំណត់

មិនប្រាកដ ជ្រុះទីណា ទោះជិតឆ្ងាយ

តែងញាប់ញ័រ តាមលោកធមិ បក់ផាត់ផាយ

នាំចិត្តកាយ ឱ្យនឿយណាយ ចាកទិសដៅ ។

*ដោយឧបាសិកា* ***ខិម លក្ខណា***



# សូមកុំភ្លេចធាតុដើម

សក់ រោម ក្រចក ធ្មេញនិងស្បែក
ជាធាតុលោកចែកថាមិនដឹង

ទាំងសាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង
ដល់ពេលនឹកខឹងៗអ្នកណា?

បេះដូង ទាច ថ្លើម វាវ ក្រពះ
សុទ្ធតែប្រែផ្លាស់អនត្តា

សួត ពោះវៀនធំគួរអនិច្ចា
ពោះវៀនតូចផងណាអាហារថ្មី ។

អាហារចាស់ និងខួរក្នុងក្បាល
វិនាសគ្រប់កាលជាប្រក្រតី

ប្រមាត់ ទឹកស្លេស្ម ខ្ទុះ ឈាមក្តី
កើតពីបច្ច័យហេតុទាំងអស់ ។

សម្បោរ ខ្លាញ់ខាប់ ញើស ទឹកភ្នែក
ប្រសិនបើឆែកគ្រប់កៀនកោះ
ខ្លាញ់រាវ ទឹកមាត់ បដិកូលស្មោះ
គ្មានមនុស្សសត្វសោះនៅពីក្នុង ។
ទឹករំអិល ទឹកមូត្រ ក៏ជាធាតុ
ផ្តុំបិទចងសៀតដើមដល់ចុង
កើតជារូបមនុស្សមួយទាំងស្រុង
តែកុំជឿស្លុងភ្លេចធាតុដើម ។

*ដោយឧបាសិកា **ខិម លក្ខណា***



# កុំដាច់ចិត្តក្នុងរសអាហារ

ព្រះពុទ្ធជាម្ចាស់ប្រៀបឧបមា
កវឡីការាហារមានន័យ
ដូចជាភរិយានិងស្វាមី
បីទាំងកូនខ្ចីដើរផ្លូវឆ្ងាយ ។
ផ្លូវកន្តារៈកើតទុរ្ភិក្ស
ព្រោះខ្វះបាយទឹកផ្គត់ផ្គង់កាយ
មានចោរ-សត្វកាចនាំអន្តរាយ
អមនុស្សទាំងឡាយបៀតបៀនផង ។
ដើរឃ្លូវស្បៀងតិចដាច់អាហារ
គិតគ្នាប្រហារកូនតែម្តង
យកសាច់បរិភោគដើម្បីឆ្លង
វាលធំកន្លងជាផ្លូវឆ្ងាយ ។

ពេលលេបសាច់កូនពិចារណា
មិនមែនជាការលេងសប្បាយ
មិនមែនដើម្បីតាក់តែងកាយ
ជាប់ចិត្តរីករាយក្នុងការឆី ។
ពីព្រោះជាសាច់កូនបង្កើត
ជាទីស្រឡាញ់ពេញហឫទ័យ
សាច់នោះនៅឆៅហើយទន់ខ្ចី
គ្មានរសជាតិប្រៃសាបសូន្យឈឹង ។
មិនបានចម្អិនក្លិនអសោច
ប៉ុន្តែយ៉ាងហោចគ្រាន់ទីពឹង
បរិភោគបានរស់មានលំនឹង
ដើរឆ្លងវាល-ស្ទឹងឱ្យដល់ត្រើយ ។
លុះដល់ទីដៅលាក់រឿងពិត
សល់សាច់កប់ជិតរួចស្រេចហើយ

មិនអួតប្រាប់ញាតិមិត្តណាឡើយ
ថាបានបរិភោគសាច់កូនឯង ។

រឿងនេះប្រៀបដូចពុទ្ធបរិស័ទ
បានលាភហើយស្ងាត់មិនសម្ដែង

មិនអួតមិនមើលងាយគ្នាឯង
ប្រឹងប្រែងតម្រង់ផ្លូវជីវិត ។

អនុគ្រោះដល់ព្រហ្មចរិយធម៌
ថ្លាស្អាតបវរល្អពេកពិត

ដែលគួរក្រេបផឹកហើយប្រព្រឹត្ត
ជម្រះផ្លូវចិត្តទៅនិព្វាន ។

*ដោយឧបាសិកា ខ្ទឹម លក្ខណា*

## សុខទុក្ខជាផលរបស់កម្ម

មិនមានអ្នកណាធ្វើសុខទុក្ខ
លំបាកស្រណុកចែកគ្នាទេ

វិបាកកើតពីកម្មបុព្វេ
ដែលម្ចាស់យើងគេបានធ្វើហើយ ។

បើគេធ្វើ "ទុក្ខ" ឱ្យយើងបាន
គង់ធ្វើ "សុខ" បានពុំខានឡើយ

បើធ្វើសុខឱ្យគេកើតហើយ
ម្ដេចមិនធ្វើឱ្យខ្លួនឯងផង?

ឱ្យបានរួចផុតពីជរា
ព្យាធិមរណាដូចបំណង

អាសវក្កិលេសទាំងឡាយផង
ទើបឈ្មោះថា "គេឱ្យទុក្ខខ្លួន" ។

*ដោយឧបាសិកា* ***ខិម លក្ខណា***



# កុំសេពគប់នឹងសាវេយ្យៈ

ព្រះពុទ្ធត្រាស់ថាសាវេយ្យៈ
កំនៅក្នុងអកុសលមូល
អែបអបអួតអាងជាចិត្តពុល
ពុតត្បុតបុគ្គលបិទកំហុស ។
លាក់គុនវិជ្ជាគ្មានក្នុងខ្លួន
ធ្វើហាក់មាំមួនមិនឱ្យខុស
ឃើញពួកត្រីមកក៏ត្រដុស
បង្ហាញកន្ទុយថាយើងជា ។
ហ្វូងមច្ឆជាតិដូចអ្នកដែរ
ឃើញពស់មកក្បែរក៏សសៀរ
បង្ហាញក្បាលថាយើងក៏ជា
សត្វពស់ដូចគ្នាពិតណាអ្នក ។
ចំណែកគម្ពីរអដ្ឋកថា
ព្រះអភិធម្មថាជនណាម្នាក់

ដែលប្រកបដោយសាវេយ្យៈ

មានភាពមិនជាក់ម៉ែ!ម៉េ!អ៊ឹក!។

មើលពីខាងស្តាំដូចពារពៃ

ត្រឡប់ឆ្វេងបែរដូចសត្វជ្រូក

សម្លេងដូចចៀមស្រែកប្រកូក

បើមើលទៅស្មែងដូចគោចាស់។

*ដកស្រង់ចេញពីគម្ពីរព្រះត្រៃបិដក*
*លេខ២០ ទំព័រ១១៦*

*ដោយឧបាសិកា* ***ខ្ទិម លក្ខណា***

# ព្រះន័យព្រះអគ្គសាវ័ក

ព្រះសារីបុត្រទូលព្រះថា
ហេតុខ្ញុំព្រះករុណាមិនអាល័យ
មិនត្រេកអរនឹងវេទនាបី
សូមថ្វាយសេចក្ដីដូច្នេះថា ។
វេទនាទាំងបីមិនទៀងទាត់
កើតហើយប្រាសព្រាត់គ្រប់វេលា
ទោះចិត្តបានសោយសុខវេទនា
គង់ប្រែគ្រាំគ្រាជាទុក្ខព្រួយ ។
ព្រះពុទ្ធទទួលថាសាធុ
អ្នកមានអាយុពិតជាជួយ
ការសោយអារម្មណ៍ឯណាមួយ
ក្នុងលោកទុក្ខព្រួយនឹងមានខ្លាំង ។
ការសោយវេទនាគ្រប់ប្រភេទ
**យាំកិញ្ចិវេទយិតំ តំ**

**ទុក្ខសច្ចៈ** ទុក្ខកើតខ្លាំង

បើនៅពឹងអាងធម៌លោកិយ៍ ។

ចិត្តព្រះអរហន្តមិនញាប់ញ័រ

ពេលជួបលោកធម៌ទាំងប្រាំបី

លោកដាក់ចិត្តកាយដូចផែនដី

ទទួលគ្រប់អ្វីៗដែលមកដល់ ។

*ដោយឧបាសិកា* ***ខិម លក្ខណា***



# ព្រះសម្មាសម្ពុទ្ធជាគ្រូពេទ្យ

យប់មួយត្រជាក់ខែរនោច
ព្រះចន្ទនៅតូចរះព្រាងៗ
ជួនភ្លឺជួនលិ្វតប្រែមិនទៀង
ពពកមុនភ្លៀងបាំងចន្ទបាត់ ។
ភ្លៀងធ្លាក់រន្ទះភ្លឺម្តងៗ
សូរផ្គរឆ្លើយឆ្លងទាំងយប់ស្ងាត់
មែកស្រល់រេរាំដោយខ្យល់ផាត់
អ្នកភូមិលក់បាត់ក្នុងនិទ្រា ។
ខ្ញុំបើកបង្អួចសម្លឹងមេឃ
ចិត្តនឹកសង្វេគយើងគ្រប់គ្នា
កើតមកត្រូវជួបចាស់ជរា
ថែមទាំងរោគាតាមប្រល័យ ។

សង្វេគនឹងស្លាប់ដូចគល់ឧស
កំពុងនៅរស់ប្រែក្សិណក្ស័យ
សង្វេគសត្វលោកខ្លាចទុក្ខភ័យ
ប៉ុន្តែគ្មានអ្វីអាចជួយបាន ។
សង្វេគម្យ៉ាងទៀតនឹងអ្នកក្រ
រស់ទាំងត្រដរមិនសុខសាន្ត
សង្វេគអ្នកមានខ្លះក៏បាន
ទុក្ខសោករំខានប្រហែលគ្នា ។
ជីវិតជាទុក្ខព្រោះមិនទៀង
វាំង-ធ្លាក់ដូចភ្លៀងគ្រប់វេលា
ផ្លាស់ខ្មៅតរនោចដូចចន្ទ្រា
ជួនឃោលវេរាដូចចុងស្រល់ ។
ដួងខែគង់តែពពកបាំង
ជួនផ្គរលាន់ខ្លាំងដោយមេខ្យល់

សត្វលោកងុយងោកក្នុងកម្មផល

គប្បីស្វែងយល់រសធម្មា ។

ព្រះធម៌មានគុណយ៉ាងស័ក្តិសិទ្ធិ

ព្យាបាលរោគចិត្តឱ្យបានជា

ព្រះពុទ្ធជាគ្រូពេទ្យសួគ៌ា

ពួកយើងរាល់គ្នាជាអ្នកឈឺ ។

*ដោយឧបាសិកា* **ខិម លក្ខណា**



## ប្រយ័ត្នត្រូវអនន្តរិយកម្មដោយមិនដឹងខ្លួន

កាលកូននៅតូចពុកម៉ែថែទាំ
ចិញ្ចឹមថ្នាក់ថ្នមឱបថើបបំពេ
យកផ្ទើមេដោះមិនអស់ចិត្តទេ
នឹកភ័យក្រែងគេមើលកូនមិនល្អ។
កូនឈឺម្តងៗពុកម៉ែភ័យព្រួយ
បួរគ្នាបីស្ទួយដោយចិត្តស្មោះស
ថ្នាំថ្លៃប៉ុណ្ណាមិនត្អូញខ្លាចក្រ
លួងចិត្តអង្វរឱ្យកូនឆាប់ជា។
ពុកម៉ែយកទ្រូងពាំងគ្រាប់ជួសកូន
សុខចិត្តបាបខ្លួនទទួលកម្មពៀរ
ពេលកូនមានទុក្ខម៉ែពុកធានា
រ៉ាប់រងធ្វើជាខ្ញុំកូនដាច់ថ្លៃ។

មិនតែប៉ុណ្ណោះថែមមូត្រលាមក

គំរើកួតឈ្លក់ម៉ែកាន់ពេញដៃ

មិននឹកខ្ពើមឆ្អើមស្រឡាញ់បុត្រថ្លៃ

ថ្នមកូនយប់ថ្ងៃវិស័យកែវភ្នែក ។

ចំណែកឪខ្លះបឹតបៀមលេបខ្ទុះ

អាសូរកូនប្រុសឈឺចាប់អនេក

ឪនឹកខ្លោចចិត្តអាណិតកូនពេក

កើតរោគចម្លែកឃុំស្រែកឥតល្ហែ ។

លុះម៉ែពុកឈឺកូនថារវល់

មានប្រាក់អាងជួលអ្នកផ្សេងឱ្យថែ

យកលេសធ្វើការរកលុយមើលម៉ែ

បាត់មុខរាប់ខែយូរៗឃើញម្តង ។

ពុកម៉ែឈឺខ្លាំងពេទ្យគិតចង់ជួយ
កូនថាកុំព្រួយអាណិតគាត់ផង
ទុកគាត់រស់យូររីតឈឺកន្លង
ឱ្យម៉ែពុកឆ្លងផុតការចុកចាប់ ។
ប្រៀបមកខ្លួនយើងទោះឈឺយ៉ាងណា
ខ្វាក់ខ្វិនពិការគង់មិនចង់ស្លាប់
ផ្លូវបុណ្យមិនដើរទៅដើរផ្លូវបាប
កងចក្ររាប់ហាបឃើញជាភួងផ្កា ។

*(សូមមេត្តាទុកឱ្យមាតាបិតាអស់បុណ្យតាមសម្រួល)*

*ដោយឧបាសិកា* **ខិម លក្ខណា**



# កតញ្ញុតា
# ភាពៈនៃអ្នកដឹងគុណ

កតញ្ញុតា មានន័យប្រាប់ថា ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ
ប្រាប់ឱ្យតបគុណ។

មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលត្រូវសាបព្រោះ។

បណ្ដុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឱ្យមានមោះ
បុណ្យនឹងកើតកើន ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ
កុំលុបគុណចោល។

ពុកម៉ែឈឺខ្លាំងពេទ្យគិតចង់ជួយ
កូនថាកុំព្រួយអាណិតគាត់ផង
ទុកគាត់រស់យូររឺតឈឺកន្លង
ឱ្យម៉ែពុកឆ្លងផុតការចុកចាប់ ។
ប្រៀបមកខ្លួនយើងទោះឈឺយ៉ាងណា
ខ្វាក់ខ្វិនពិការគង់មិនចង់ស្លាប់
ផ្លូវបុណ្យមិនដើរទៅដើរផ្លូវបាប
កងចក្ររាប់ហាបឃើញជាភួងផ្កា ។

*(សូមមេត្តាទុកឱ្យមាតាបិតាអស់បុណ្យតាមសម្រួល)*

*ដោយឧបាសិកា* **ខិម លក្ខណា**



# កតញ្ញុតា
## ភាវៈនៃអ្នកដឹងគុណ

កតញ្ញុតា មានន័យប្រាប់ថា ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះជាគ្រូ
ប្រាប់ឱ្យតបគុណ។

មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលត្រូវសាបព្រោះ។

បណ្ដុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឱ្យមានមោះ
បុណ្យនឹងកើតកើន ចម្រើនឥតខ្ចោះ ត្រូវមានចិត្តស្មោះ
កុំលុបគុណចោល។

កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល
មាត់ថាត្រូវតប គុណកុំច្បោលៗ ធ្វើដែរស្រោលៗ
សោះតែគេថា ។

ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេសនា
សរសើរញឹកញាយ មានក្នុងសាស្ត្រា គម្ពីរដីកា
គួរយើងចងចាំ ។

ចេះចាំហើយធ្វើ ដោយចិត្តអើពើ ឱ្យស៊ប់ឱ្យស៊ាំ
ឱ្យស្និទ្ធដឹងគុណ គុណតែងថែទាំ ពុំមែនខ្ជេចខ្ជាំ
ព្រោះតបគុណទេ ។

ជនមានចិត្តខ្សោយ ច្រើនតែធ្វេសធ្លោយ រមិលគុណគេ
អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហែសធ្វេសទ្វេ
ព្រងើយកន្តើយ ។

អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ
ជនប្រុសស្រីនោះ ពុំមានសុខស្បើយ យូរប៉ុន្មានឡើយ
រវែងតែធ្លាក់ខ្លួន។

កំពុងបានសុខ ស្រាប់តែមានទុក្ខ ចេញមកផ្ទួន១
ឱ្យផលកំណាច ឃោរឃៅឥតស្ងួន ទោសមកពីខ្លួន
រមិលគុណគេ។

ទេព្ដាគេខឹង ព្រោះខ្លួនរឹងត្អឹង អាងបុណ្យបុព្វេ
ទោសបច្ចុប្បន្ន ជិះជាន់ឥតល្ហែ ភ័ព្វព្រេងបុព្វេ
បើមានក៏ផ្អាក។

ទោសរមិលគុណ រារាំងមុខបុណ្យ ព្រេងឱ្យសម្រាក
បង្អង់ឈប់សិន បាបថ្មីវិបាក ឱ្យផលឥតស្រាក
ព្រោះបានឱកាស។

បុណ្យបាបចាស់ថ្មី តែងតែវំពៃ ពុំមែនផ្ដេសផ្ដាស
កាលមានចន្លោះ ត្រូវពេលសស្រាស ហាក់ដូចប្រកាស
ប្រាប់ថាត្រូវអញ ។

ចេញមុខផ្ដល់ផល សុខទុក្ខឱ្យដល់ ជនណាដែលកាញ់
កសាងបង្កើត កំណើតជាអញ អញជាសម្លាញ់
ត្រូវអញឱ្យផល ។

វីបុណ្យឬបាប ដែលមានសភាព ជាកម្មតែងផ្ដល់
សុខទុក្ខឱ្យជន អ្នកធ្វើឱ្យដល់ នូវក្ដីសល់វល់
ឬក្ដីសុខសាន្ត ។

បាបតែងរាំង បុណ្យឱ្យនៅគាំង ផ្អាកសិនពុំបាន
ចេញមុខឱ្យផល ជាសុខសម្រាន្ត អ្នកធ្វើតែងបាន
ទទួលរងទុក្ខ ។

បុណ្យក៏រារាំង បាបឱ្យនៅគាំង ផ្អាកពុំចេញមុខ
ព្រោះមានឱកាស បុណ្យផ្ដល់ក្ដីសុខ សុទ្ធតែមានមុខ
ទីទៃពីគ្នា ។

ហេតុនោះគួរជន កុំនៅទម្រន់ ក្នុងក្ដីខ្ជិលខ្ជា
គួរកសាងបុណ្យ មានគុណមហិមា ទើបបានឈ្មោះថា
អ្នកស្រឡាញ់ខ្លួន ។

វត្តឧណ្ណាលោម, ភ្នំពេញ ថ្ងៃទី ២៦ ធ្នូ ព.ស. ២៥១២ / គ.ស. ១៩៦៨

ព្រះហស្តលេខា
សម្ដេចព្រះសង្ឃរាជ
ជ.ណ.ជោតញ្ញាណោ

## បទលើកតម្កើងព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណិស
ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ងំគ្រស្វាគម
ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក
ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា
នៃព្រះសម្ពុទ្ធធំចម្បង

ចូរយើងរាល់គ្នា យកចិត្តចាំចង

នឹកដល់ព្រះអង្គជាអម្ចាស់ ។

ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា

សុទ្ធសឹងតែជាពុទ្ធសាសនិ៍

ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់

ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា ។

សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត

រុងរឿងវិសុទ្ធថ្លៃថ្លា

ហើយមានជ័យជោគ ផ្សាយពេញលោកា

ដោយជនជ្រះថ្លារាប់ច្រើនលាន ។

មានចិត្តស្នេហា គោរពបូជា

ចំពោះព្រះធម៌ដ៏កល្យាណ

ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ

ប្រាថ្នាចង់បានសេចក្ដីសុខ ។

យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត

កាន់ធម៌នឹងបានផុតទុក្ខ

រួបរួមមេត្រី ពីនេះទៅមុខ

ទើបនឹងបានសុខក្សេមក្សាន្តត្រាណ ។

ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត

ឆ្ពោះទៅកាន់ឋាននិព្វាន

ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត

ជាតិយើងនឹងបានសោយសុខា ។

*និពន្ធដោយ សម្ដេចព្រះសង្ឃរាជ*

**ជ.ណ.ជោតញ្ញាណោ**

# បទសូត្រដាក់ទង់ព្រះពុទ្ធសាសនា

ក្រុមយើងអ្នកកាន់សាសនា
ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី
គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់
រុងរឿងឫទ្ធិរង្គប្រសើរបវរ
ឆ្លៀលឆ្លាត់កាយឆើតឆាយល្អ
ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី
កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា
កាលដែលនៅជាព្រះពោធិសត្វ ។

រស្មីពណ៌ខៀវនោះណា
កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍បាត់
កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ ។

រស្មីពណ៌លឿងភ្លឺថ្លា
កាលដែលទ្រង់អារសាច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺឱភាស
ព្រះឥន្ទជាងមាសទ្រង់វ័យបណ្ឌិត ។

រស្មីក្រហមនោះណា
កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស្មូប្តូរជីវិត
កាត់បេះដូងបិទធ្វើថ្នាំមាតា ។

រស្មីពណិសសុទ្ធសាធ

កាលដែលព្រះបាទវេស្សន្តរក្សត្រា

ឱ្យដីរសសោភា

ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។

រស្មីពណិដូចជើងហង្ស

កាលមាតាទ្រង់យក្ខចាប់យកបាន

វិជ្ជាធរអារសាច់ប្រាណ

ឱ្យយក្ខសាមានស្រុះប្តូរជីវិត ។

រស្មីពណិផ្លេកពណ្ណរាយ

កាលជាទន្សាយឈ្មោះសោមបណ្ឌិត

ឱ្យទានសាច់ឈាមជីវិត

ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។

រស្មីខៀវលឿងក្រហម

សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ

ត្រូវជាប្រាំមួយប្រការ

ទាំងចាស់កុមារចងចាំទុកអើយ ។

*និពន្ធដោយ សម្ដេចព្រះសង្ឃរាជ*

**ជ.ណ.ជោតញ្ញាណោ**



# សំណោករបស់យាយ

នាម **សាន-សុជា** សូមលើកហត្ថា
សរសេរកូនច្បាប់ ជូនញាតិសន្តាន
ជាទីសណ្ដាប់ បើមិនគួរគាប់
សូមអត់ទោសពៃរ៍ ។

នេះនឹងបរិយាយ ពីការសោកស្ដាយ
មនុស្សចាស់ស្រី១ ដែលគាត់ស្រណោះ
កាលនៅក្មេងវ័យ តែងជាកាព្យខ្លី
មានន័យតទៅ ។

ស្ដាយអើយសែនស្ដាយ ស្ដាយរូបរាងកាយ
ដែលចាស់ហួសទៅ កាលនៅក្រមុំ
រូបគ្មានហ្មងសៅ កម្លោះតាមផ្លូវ
ចែចូវគ្រប់គ្នា ។

ស្តាយអើយសែនស្តាយ ស្តាយសក់រសាយ
ក្រាលគ្រប់លើស្មា ដល់ពេលខ្លួនចាស់
គេលែងត្រូវការ សូម្បីតែតា
ក៏លែងមើលដែរ ។

ស្តាយអើយសែនស្តាយ ស្តាយធ្មេញទាំងឡាយ
រឹងមាំគួរដែរ ដល់ពេលខ្លួនចាស់
ក្រឡាស់ប្រួលប្រែ បាក់ជាហូរហែ
កែក៏មិនបាន ។

ស្តាយអើយសែនស្តាយ អាណិតរូបកាយ
ជរារុញច្រាន ដល់ពេលខ្លួនចាស់
ភាពស្រស់ប៉ុន្មាន ចោរជរាបាន
លួចយកទាំងអស់ ។

ស្តាយអើយសែនស្តាយ សាច់ស្បែកទាំងឡាយ

ម៉ដ្ឋល្អឥតខ្ចោះ ដល់ពេលខ្លួនចាស់
ជ្រួញស្វិតកក្រោះ ពួកអ្នកកម្លោះ
គេលែងត្រូវការ ។

ស្ដាយអើយសែនស្ដាយ វង់ភ័ក្ត្រឆើតឆាយ
គ្មានទាស់ត្រង់ណា ប្រុសណាឃើញហើយ
តែងលង់ចិន្ដា សូម្បីអាចារ្យ
ក៏សូត្រធមិខុស ។

ស្ដាយអើយសែនស្ដាយ ក្រចកទាំងឡាយ
ភ្លឺល្អទាំងអស់ សមនឹងម្រាមដៃ
លូតលូន់ឥតខ្ចោះ ឥឡូវប្រែអស់
លែងស្រស់ទៀតហើយ ។

ស្ដាយនៃត្រាខ្ញុំ កាលនៅក្រមុំ
ភ្នែកពុំព្រិលឡើយ ដល់ពេលខ្លួនចាស់

មើលលែងច្បាស់ហើយ ជាងវ៉ែនតាអើយ
ជួយលែលកផង ។

កាលរូបនៅក្មេង ពេលខ្ញុំតាក់តែង
រូបកាយម្តង១ ឆ្លុះមើលកញ្ចក់
ស័ក្តិសមឥតហ្មង ហុកឆ្នាំកន្លង
លោកញ្ចក់ហើយ ។

កាលនៅក្រមុំ រូបសម្រស់ខ្ញុំ
សមគ្មានទាស់ឡើយ សូម្បីលោកសង្ឃ
ក៏មិនព្រងើយ មិនសង្រួមហើយ
ហេងស៊យដាច់សីល ។

និយាយយ៉ាងនេះ មិនមែនត្រិះរិះ
ដោយគំនិតខិល មិនមែនបង្អាប់
លោកយាយទ្រង់សីល ដោយមាត់រអិល
ចេះតែថាទេ ។

តែថាភាពពិត　　　តែមានជីវិត
មិនថាយើងគេ　　　កើតមកត្រូវចាស់
គ្មាននៅសល់ទេ　　　ថៅកែខ្ញុំគេ
ចាស់ឥតសល់សោះ ។

បន្ទាប់ពីចាស់　　　យើងបានឃើញច្បាស់
ថាស្លាប់ទាំងអស់　　　បិតាភរិយា
ទ្រព្យារបស់　　　យកមិនបានសោះ
បោះចោលទទេ ។

ដូច្នេះគួរគិត　　　ត្រូវមានគំនិត
រួតរះគ្មាន់គ្មេរ　　　ប្រញាប់សាងទាន
កាន់សីលនឹងគេ　　　កុំនៅទំនេរ
ដេរកូននៅផ្ទះ ។

រៀនព្រះសទ្ធម្ម　　　ដើម្បីអប់រំ

ចិត្តឱ្យល្អុះ កុំនៅអែអង់
រង់ចាំខ្លួនចាស់ ដល់ស្លាប់លែងច្បាស់
ថាទាស់ចាស់ជ្រុល ។

ធម៌ជាឱសថ ពិសេសបំផុត
បំបាត់ជាតិពុល បើសត្វណាត្រាប់
ច្បាប់ព្រះពន្យល់ សត្វនោះនឹងដល់
ព្រះនិព្វានហោង ។

*ថ្ងៃអាទិត្យ ទី១៥ ខែកក្កដា* *ព.ស ២៥៤៥*
*គ.ស ២០០២*



# មានះរបស់តា

ពោលតែរឿងយាយ ៗចោទថា
ម្ដេចចំណែកតាមិនបរិយាយ
រឿងនេះហាក់ដូចជាមើលងាយ
ថាឱ្យតែយាយដូចមិនត្រូវ ។
រឿងយាយគាត់ចោទពិតជាសម
ខ្ញុំនឹងខិតខំកែតម្រូវ
សរសេរតម្រាចារប៉ះប៉ូវ
បើខុសឬត្រូវសូមមេត្តា ។
រឿងតាជារឿងដាច់ដោយឡែក
គាត់ច្រើនពឹងផ្អែកលើវិជ្ជា
ដែលគាត់ធ្លាប់រៀនធ្លាប់សិក្សា
សូមរំឭទេសនាក៏លែងស្ដាប់ ។

តាខ្លះពីក្មេងគាត់ធ្លាប់បួស
ច្រើនតែចេះហួសតម្រាច្បាប់
អាងយសអាងស័ក្តិល្បីសួរស័ព្ទ
លែងចេះត្រងត្រាប់ច្បាប់ព្រះដើម ។
អ្នកខ្លះធ្លាប់រៀនធ្លាប់បានបួស
ទេសនាពីរោះយសសមៀម
សីកមួយរំពេចភ្លេចធាតុដើម
ល្ងីល្ងើជ្រួលជ្រើមឡប់លែងជា ។
ខ្លះរីតតែដឹងរីតចចេស
អ្នកផងគ្មានចេះជាងអាត្មា
អាងនាមអាងឈ្មោះជាអាចារ្យ
ប្រាជ្ញលោកទេសនាថាមិនត្រូវ ។
ខ្លះរីតតែល្បីរីតតែល្ងើ
ជ្រប់ងប់ភ្លីភ្លើដើរខុសផ្លូវ

ឃើញអ្នកដទៃទាបដូចស្មៅ
សំដៅថាមានតែអាត្មា។
មិននិយាយលោកយាយក៏ដឹង
ថាសព្វថ្ងៃហ្នឹងវាយ៉ាងណា
ការរៀនឬស្ដាប់ព្រះធម្មា
យាយច្រើនជាងតារាល់តែថ្ងៃ។
រឿងនេះនិយាយតាមគំហើញ
ដែលខ្ញុំធ្លាប់ឃើញក្នុងលោកិយ
សូមលោកយាយជួយវិនិច្ឆ័យ
ថាជន្លេនដីវាយ៉ាងណា។
វារស់ក្នុងត្រឡោកផ្កាប់
អួតខុសសណ្ដាប់ខុសតម្រា
ក្បាលប៉ះត្រឡោកនោះកាលណា

សម្គាល់អាត្មាធំជាងមេឃ ។
ឬដូចកង្កែបក្នុងកូនថ្លុក
បានត្រឹមសំកុកគំហកស្រែក
ចំកោងអួតខ្លួនជាអនេក
លើដីក្រោមមេឃគ្មានអ្នកដល់ ។
រឿនេះមិនមែនចេះតែស្តី
ពោលពាក្យព្រៃផ្សៃគ្មានហេតុផល
សូមលើកគ្រឿងអាងមកតម្កល់
**ឆឹង ភាន** ពន្យល់ដូច្នេះថា ។
"មានះជើងឯកប៉ែកខាងរឹង
លង់ម្ទឹងគង់មិនព្រមញ៉មអ្នកណា
មានះនេះមានដរាបណា
ប្រយោជន៍ខ្លឹមសារត្រូវអន្តរាយ" ។

ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះចុះ

អស់លោកសប្បុរសផងទាំងឡាយ

ខ្ញុំមិនមែនពោលពាក្យឡែ់បខាយ

មើលងាយតាៗទាំងអស់ទេ។

និយាយសំដៅតាៗខ្លះ

ដែលគាត់មានះឯណោះទេ

បើមានប៉ះពាល់សូមកុំជេរ

គិតគូរកែប្រែប្រសើរជាង។

*ថ្ងៃអាទិត្យ ទី២២ ខែកក្កដា* *ព.ស ២៥៤៥* / *គ.ស ២០០២*

# អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ

ធម្មាចារ្យ គម្ពីរបញ្ញោ **វួច សុធី**

ឧទ្ទេសាចារ្យ សីលសំវរោ **ស៊ូ សាមុត**

សាមណេរ បញ្ញាបរមោ **ឈាត ម៉ុនឆាត**

សាមណេរ ព្រហ្មឃោសកោ **ឈិត ម៉ុនធឿន**

សាមណេរ ញាណភទ្ទោ **សុខ ទុធដែន**

សាមណេរ ខន្តិធរោ **ជឹម បូរិន**

# សៀវភៅធម៌ដែលរៀបរៀងដោយ
# ភិក្ខុវជិរប្បញ្ញោ សាន សុជា

១-ព្រះធម្មបទ៣១គាថា

២-អក្ខរវិធី និងធម៌នមស្ការ

៣-រលកលោកធម៌

៤-ព្រះធម្មបទ៣០គាថា

៥-ប្រយោជន៍ ៣ ប្រការ

៦-ជីវិត (Life)

៧-បងប្អូនជួបគ្នាមួយគ្រាម៉ាននន័យ

៨-អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៤

៩-អភិធម្មសង្គណី តិកមាតិកាសង្ខេប

១០-ជីវិតពិតជាត្រូវការធម៌

១១-តើនរកមានដែរឬទេ ?

**ព្រះធម៌គឺជាផែនទីនៃជីវិត**

# ប៉ុស្តិ៍វិទ្យុដែលកំពុងផ្សព្វផ្សាយព្រះធម៌សំដែងដោយភិក្ខុវជិរប្បញ្ញោ សាន សុជា

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 100.50 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧.00 pm រៀងរាល់ល្ងាច ។

☞ ខេត្តពោធិ៍សាត់ វិទ្យុ FM 98.50 MHz

-ចាប់ពីម៉ោង ៧.00 pm ⇨ ៨.00 pm រាល់ល្ងាចថ្ងៃសីល ។

☞ ខេត្តកំពង់ធំ វិទ្យុ FM 107.30 MHz

-ចាប់ពីម៉ោង ៦.00 am ⇨ ៦.៣០ am រៀងរាល់ព្រឹក ។

☞ ក្រុងកំពង់សោម វិទ្យុ FM 92.00 MHz

-ចាប់ពីម៉ោង ៦.៣០ pm ⇨ ៧..00 pm រៀងរាល់ល្ងាច ។

☞ ខេត្តកំពង់ចាម វិទ្យុ FM 92.50 MHz

-ចាប់ពីម៉ោង ៧.00 pm ⇨ ៧.៣០ pm រៀងរាល់ល្ងាច ។

☞ ខេត្តសៀមរាប វិទ្យុ FM 102.50 MHz

-ចាប់ពីម៉ោង ៥.00 am ⇨ ៥.៣០ am រៀងរាល់ព្រឹក ។

**ការសំដែងនូវព្រះសទ្ធម្មនាំមកនូវសេចក្ដីសុខ**

# ឆ្នាំថ្មី !!!

បុណ្យចូលឆ្នាំថ្មី ប្រុសស្រីសប្បាយ

ហាក់ដូចឃ្លាតឆ្ងាយពីក្តីមរណា

តែបើពិនិត្យអាយុសង្ខារ

ពិតឃើញច្បាស់ថាជិតអស់ពេលហើយ ។

ហាមបោះពុម្ពផ្សាយឬធ្វើអាជីវកម្មដោយមិនមានការអនុញ្ញាតពីម្ចាស់សៀវភៅ